00417239

លេខ / No: D268/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 12 / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Huy

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

ភាសាដើម៖ ខ្មែរ /អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 22 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Huy

# ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ

**សហព្រះរាជអាជ្ញា**
អ្នកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
ខៀវ សំផន
អៀង សារី
កាំង ហ្គេកអ៊ាវ ហៅ ឌុច
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
នី ច័ន្ទឌី ឡោ ជុនធី
គង់ ពិសី ហុង គីមសួន
យុង ផានិត គីម ម៉េងឃី
ម៉ុច សុវណ្ណារី ស៊ិន សុវន
ជេត វណ្ណលី ពេជ អង្គ
Silke STUDZINSKY
Phillipe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

**មេធាវីការពារក្តី**
សុន អរុណ Michiel PESTMAN
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
ស សូវ៉ាន Jacques VERGES
ការ សាវុត្ថ François ROUX
Marie-Paule CANIZARES

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនដទៃ** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** និង**ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.បានឃើញវិធាន ៥៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ("វិធានផ្ទៃក្នុង")

បានឃើញវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុង)

បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៩ (D146) ("ដីកាបញ្ជូនរឿងទៅពិនិត្យ")

បានឃើញសំណើរបស់សហព្រះរាជអាជ្ញា សុំពេលវេលាបន្ថែមដើម្បី ឆ្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៩ (D146/1)

បានឃើញដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៩ សម្រេចលើសំណើសុំពេលវេលាបន្ថែម (D146/2)

បានឃើញចម្លើយរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ តបចំពោះដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម (D146/3)

បានឃើញសំណើលើកទីពីររបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩ (D188) ("សំណើសុំ")

បានឃើញការឆ្លើយតបរបស់មេធាវីការពារក្ដី អៀង សារី ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៩ (D188/3) ("ការឆ្លើយតបរបស់មេធាវីការពារក្ដី អៀង សារី")

បានឃើញការឆ្លើយតបរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ទាក់ទិននឹងការជំទាស់របស់មេធាវីការពារក្ដី ចំពោះទទ្បីករណ៍ ស្ដីពីយុត្តាធិការដែលបានលើកឡើងនៅក្នុងសំណើសុំលើកទីពីររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៩ (D188/4) ("ការឆ្លើយតបរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ")

បានឃើញការអនុញ្ញាតបន្ថែម ស្របតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ចំពោះដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ (D146/4)

បានឃើញសេចក្ដីប្រកាសបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងចម្លើយតបចំពោះដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ (D146/5)

បានឃើញសំណើលើកទីបួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបទឧក្រិដ្ឋទាក់ទិននឹងផ្លូវភេទ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៩ (D268) ("សំណើសុំបន្ថែម")

**ការរំលឹកឡើងវិញអំពីនីតិវិធី**

១. នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានធ្វើដីកាបញ្ជូនរឿងទៅពិនិត្យទៅការិយាល័យសហព្រះរាជអាជ្ញា (កសព) ផ្អែកទៅលើពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលយោងទៅលើអង្គហេតុ ដែលទំនងបង្កើតជាអង្គហេតុថ្មី ស្របតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង ដូចជា ការចោទប្រកាន់ថាមានការកើតឡើងនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ[1]។

២. នៅក្នុងការឆ្លើយតបរបស់ខ្លួន ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ក.ស.ព បានស្នើសហចៅក្រមស៊ើបអង្កេត ឱ្យស៊ើបសួរលើការចោទប្រកាន់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមាននៅក្នុងពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន[2] ចំនែកឯពាក្យសុំផ្សេងទៀត ក.ស.ព បានអះអាងថា មិនមានការចោទប្រកាន់អំពីទំនាក់ទំនងផ្លូវភេទដោយបង្ខំទេ ប៉ុន្តែ ក.ស.ព បានចាត់ទុកថាវាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3]។ ក.ស.ព ក៏បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរលើករណីផ្សេងទៀតនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានចោទប្រកាន់ប្រសិនបើវាអាចជួយកំណត់បានពីយុត្តាធិការ ឬទម្រង់នៃការទទួលខុសត្រូវ[4]។ បន្ទាប់មក ក.ស.ព បានបំភ្លឺថា សហចៅក្រមស៊ើបអង្កេត អាចស៊ើបសួរលើករណីរៀបអាពាហ៍ពិពាហ៍ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ផ្សេងទៀត ដែលខ្លួនយល់ឃើញថា ចាំបាច់[5]។

៣. ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបដែលបានធ្វើនៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩ បានអះអាថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាបទឧក្រិដ្ឋស្ថិតនៅក្រោមច្បាប់អន្តរជាតិហើយថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អាចត្រូវបានចាត់ទុក ដូចជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត ការរំលោភផ្លូវភេទ ការធ្វើឱ្យទៅជាទាសករ ឬការមានគភ៌ដោយបង្ខំ[6]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើថាការកំណត់បទឧក្រិដ្ឋទាំងនេះ ត្រូវតែ

---

[1] D146 ទំព័រ ២។

[2] D146/3 កថា. ២។

[3] D146/3 កថា. ៣-៥។

[4] D146/3 កថា. ៦។

[5] D146/4, ដូចបានបកស្រាយរួចហើយទាក់ទិននឹងការកំណត់បទល្មើសដែលអាចមាន ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងទៀត (D146/5 កថា. ៣)។

[6] D188 កថា. ៥-២៩។

ធ្វើការស៊ើបសួរ និងបានផ្តល់បញ្ជីឈ្មោះបុគ្គលដែលត្រូវស្តាប់ចម្លើយ[7]។ នៅក្នុងសំណើសុំបន្ថែម ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បន្ថែមនូវឈ្មោះអ្នកដែលត្រូវស្តាប់ចម្លើយ[8] និងបានផ្តល់ឈ្មោះមនុស្សបីនាក់សម្រាប់ជាការពិចារណាក្នុងជ្រើសរើសធ្វើជាអ្នកជំនាញ[9]។ សំណើសុំបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានស្នើសុំឱ្យមានការស្តាប់ចម្លើយដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតជាស្ត្រី ដែលទទួលបានការបណ្តុះបណ្តាលពីបញ្ហាយ៉េនឌ័ និងអ្នកបកប្រែ ដែលទទួលបានការបណ្តុះបណ្តាលពីបញ្ហាយ៉េនឌ័ ផងដែរ[10]។

៤. ការឆ្លើយតបរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៩ បានអះអាងថា ការឆ្លើយតបរបស់ ក.ស.ព ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតយោងតែទៅលើបញ្ជីឈ្មោះមនុស្សដែលមាននៅក្នុងសំណើសុំប៉ុណ្ណោះ[11] និងថា ការលើកឡើងរបស់ ក.ស.ព ពីបញ្ហាស៊ើបសួរ ដើម្បីបញ្ជាក់ពីយុត្តាធិការ ឬទម្រង់នៃការទទួលខុសត្រូវ គឺមានលក្ខណៈស្រពិចស្រពិលដែលមិនអាចទទួលយកបាន[12]។ លើសពីនេះទៀត មេធាវីការពារក្តី អៀង សារី បានអះអាងថា មិនឃើញមានមូលដ្ឋានច្បាប់ណាមួយរបស់ អ.វ.ត.ក ដែលអាចអនុវត្តបានសម្រាប់ករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ[13]។

៥. ការឆ្លើយតបរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៩ បានអះអាងថា មិនមានយុត្តាធិការណាមួយដែលគ្របដណ្តប់លើបទឧក្រិដ្ឋដែលបានចោទប្រកាន់ទាំងនេះទេ ប៉ុន្តែ ខ្លួនគិតថា "វាមិនមែនជាពេលវេលាសមស្របសម្រាប់មេធាវីការពារក្តីឆ្លើយតបលើបញ្ហានេះទេ"[14]។ ហេតុដូច្នេះ មេធាវីការពារក្តី ចង់បានឱ្យមានការបញ្ជាក់អះអាងថា ពួកគេ

---

[7] D188 កថា. ៣០-៣១។

[8] D268 កថា. ៨(ក)-(ខ)។

[9] D268 កថា. ៨(គ)។

[10] D268 កថា. ៨(ឃ)។

[11] D188/3 កថា. ៣។

[12] D188/3 កថា. ៤-៥។

[13] D188/3 កថា. ៧-៣២។

[14] D188/4 កថា. ៣។

អាចរក្សាសិទ្ធិរបស់ខ្លួនក្នុងការលើកបញ្ហានេះ នៅពេលសវនាបឋម ឬនៅដំណាក់កាលណាមួយផ្សេងទៀតដែលខ្លួនយល់ឃើញថាសមស្រប[15]។

## ហេតុផលនៃសេចក្ដីសម្រេច

៦. សំណើសុំ ពាក់ព័ន្ធនឹងអង្គហេតុថ្មី ដែលត្រូវបានយកចិត្តទុកដាក់ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព។ វិធាន ៥៥(៣) នៃវិធានផ្ទៃក្នុងតម្រូវថា នៅពេលដែល សហចៅក្រមស៊ើបអង្កេតរកឃើញមានអង្គហេតុថ្មី ខ្លួនត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនេះទៅ ក.ស.ព ដែលមានសិទ្ធិធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ធ្វើដូចនេះ ទើបកិច្ចស៊ើបសួរ អាចប្រព្រឹត្តទៅបានលើអង្គហេតុថ្មីនេះ។ នីតិវិធីនេះ ត្រូវបានអនុវត្តចំពោះករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត[16] និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ក.ស.ព[17]។

៧. យោងតាមវិធាន ៥៥(១០) ដើមបណ្ដឹងរដ្ឋប្បវេណី អាចស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យចេញ "ដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់កិច្ចស៊ើបសួរ"។ វិធាន ៥៥(១០) ផ្ដល់ឆន្ទានុសិទ្ធិទៅឱ្យភាគីពាក់ព័ន្ធនានា ក្នុងការកំណត់ពីខ្លឹមសារនៃសំណើសុំទាំងនេះ ចំណែកឯ សហចៅក្រមស៊ើបអង្កេតក៏មានឆន្ទានុសិទ្ធិដូចគ្នា ក្នុងការឆ្លើយតបវិញដែរ។ ទម្រង់នៃការឆ្លើយតបចំពោះសំណើសុំនីមួយៗ នឹងមានការប្រែប្រួល អាស្រ័យទៅលើប្រភេទនៃសំណើសុំ។ សម្រាប់ការចេញដីកានាពេលនេះ សហចៅក្រមស៊ើបអង្កេត យល់ឃើញថាសំណើសុំ មានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវគ្រប់គ្រាន់ដែលជួយដល់ការស្វែងរកការពិត[18]។

---

[15] D188/4 កថា. ៣។

[16] D146 ទំ. ២។

[17] D146/3, D146/4, D146/5។

[18] សូមអាន អ.វ.ត.ក, អ.ប.ជ ២៤, D164/4/13 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ១៨ វិច្ឆិកា ២០០៩ កថា. ៤៤-៤៦។

៨. ក.ស.ព បានអះអាងថា សហចៅក្រមស៊ើបអង្កេតអាចស៊ើបសួរអំពីការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមួយចំនួន ដូចបានលើកឡើងដោយ ក.ស.ព នៅក្នុងការឆ្លើយតបរបស់ខ្លួនចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩[19]។ បន្ទាប់មកទៀត ក.ស.ព បានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត អាចស៊ើបអង្កេតលើអង្គហេតុបន្ថែមផ្សេងទៀតបានបើយល់ឃើញថាចាំបាច់ ដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ គឺមានន័យថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទូទាំងប្រទេសកម្ពុជា[20]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា មិនមានការចាំបាច់ក្នុងការឆ្លើយតបចំពោះអំណះអំណាងរបស់មេធាវីការពារក្តី ដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដំបូងរបស់ ក.ស.ព មានលក្ខណៈមិនច្បាស់លាស់ត្រង់ចំនុចនេះ ពីព្រោះវាស្នើឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតលើអង្គហេតុ ដែលអាចជួយកំណត់បានពីយុត្តាធិការ ឬទម្រង់នៃការទទួលខុសត្រូវ[21]។ អំណះអំណាងនេះ មិនត្រូវបានយកមកពិចារណាទេ ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបន្ទាប់មកទៀត បានស្នើឱ្យចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទូទាំងប្រទេសកម្ពុជា។

៩. សហចៅក្រមស៊ើបអង្កេត សូមរំលឹកថា ខ្លួនមិនជាប់កាតព្វកិច្ចជាមួយនឹងការកំណត់បទល្មើសដែលបានធ្វើឡើងដោយ ក.ស.ព ទេ[22]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេត ក៏មិនត្រូវបានតម្រូវឱ្យធ្វើការកំណត់បទល្មើសណាមួយនៃអង្គហេតុទាំងនេះទេ រហូតដល់ពេលចេញដីកាដំណោះស្រាយ[23]។ ហេតុដូច្នេះ នៅក្នុងដំណាក់កាលនេះ មិនចាំបាច់មានការវិភាគស្ថាពរទៅលើភស្តុតាងនៃអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ សហចៅក្រមស៊ើបអង្កេត នឹងធ្វើការពិចារណាដោយ

---

[19] D164/3 កថា. ២-៥។

[20] D164/3 ដូចបានលើកឡើងទាក់ទិននឹងការកំណត់តាមលក្ខណៈច្បាប់ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៃការរំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងទៀត (D164/5 កថា. ៦)។

[21] D188/3 កថា. ៤-៥, យោងតាមការអះអាងរបស់ ក.ស.ព នៅក្នុង D146/3កថា. ៦។

[22] សូមអានសំណុំរឿង លេខ 001/18-07-2007-ECCC/OCIJ (អបជ ០២) D99/3/42*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី កាំង ហ្គេក អ៊ាវ ហៅ ឌុច* ៥ ធ្នូ ២០០៨ 00249846-00249887, កថា. ៣៥-៣៩។ D198/1 *ដីកាសម្រេចលើសំណើសុំបំភ្លឺធ្វើឡើងដោយសហព្រះរាជអាជ្ញា* ២០ វិច្ឆិកា ២០០៩ 00403612-00403617 កថា. ១០។

[23] វិធានផ្ទៃក្នុង (វិ.៤) ១១ កញ្ញា ២០០៩ ត្រង់វិធាន ៦៧(២)។

ម៉ត់ចត់ ទៅលើអំណះអំណាងរបស់ភាគីនានាទាក់ទិននឹងភស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅពេលគាត់តែងដីកាដំណោះស្រាយ។

១០. ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា ការបកស្រាយដែលមានលក្ខណៈសមស្របអំពីធាតុផ្សំ នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺអាចដកស្រង់ចេញពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់តុលាការពិសេសសម្រាប់ សេរ៉ាឡេអូន នៅក្នុងរឿងក្តី *AFRC*[24] ។ គួរកត់សំគាល់ថា សេចក្តីសម្រេចនេះបានរកឃើញថា ភស្តុតាងនៃទំនាក់ទំនងផ្លូវភេទដោយបង្ខំ មិនចាំបាច់តម្រូវឱ្យមានទេ ទោះបីជា ការកើតមានឡើងនូវទំនាក់ទំនងផ្លូវភេទដោយបង្ខំ អាចជាភស្តុតាងបង្ហាញពីការរងរបួសរបស់ជនរងគ្រោះក៏ដោយ។

១១. ទោះបីជា សហចៅក្រមស៊ើបអង្កេត មិនអាចកំណត់ទុកជាមុន ថាតើ នៅក្នុងដីកាដំណោះស្រាយ អង្គហេតុត្រូវបានកំណត់ជាបទល្មើសយ៉ាងដូចម្តេចក៏ដោយ ក៏សហចៅក្រម សូមធ្វើការកត់សំគាល់ថា សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *AFRC* បានសម្រេចថា អាពាហ៍ពិពាហ៍ដោយបង្ខំ អាចបង្កើតបានជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដោយសារវាជាអំពើអមនុស្សធម៌។ ដោយផ្អែកទៅលើអង្គហេតុ បទឧក្រិដ្ឋផ្សេងទៀត អាចមានការពាក់ព័ន្ធ ដូចជាករណី បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដោយសារការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ឬការរំលោភផ្លូវភេទ។ បទឧក្រិដ្ឋស្ថិតនៅក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ក៏អាចមានការពាក់ព័ន្ធដែរ ដូចជាករណី ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬធ្វើឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព។ សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា មានអង្គហេតុនៅក្នុងសំណុំរឿង ដែលបង្ហាញថា ប្តីប្រពន្ធ ត្រូវបានគេបង្ខំឱ្យរួមដំណេកជាមួយគ្នា ដែលនេះអាចបង្កើតជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិផងដែរ ព្រោះវាជាអំពើអមនុស្សធម៌មួយ ដោយសំអាងទៅលើការបង្ខំឱ្យមានគភ៌ ប្រសិនបើការវិភាគផ្លូវច្បាប់នៅក្នុងដីកាដំណោះស្រាយរកឃើញមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបែបនេះ។

---

[24] សំណុំរឿងលេខ SCSL-2004-16-A, *Brima និងជនដទៃ។ ("សំណុំរឿង AFRC ")*,សាលដីកាលើបណ្តឹងឧទ្ធរណ៍ កថា. ១៩៦។

១២. ទាក់ទិននឹងឈ្មោះមនុស្សដែលស្នើឱ្យមានការស្ដាប់ចម្លើយ ដូចមាននៅក្នុងសំណើសុំ[25] និងសំណើសុំបន្ថែមនោះ[26] សហចៅក្រមស៊ើបអង្កេត កំពុងតែធ្វើការវាយតំលៃទៅលើភស្តុតាង ហើយនឹងធ្វើការស្ដាប់អ្នកចម្លើយអ្នកដែលមានឈ្មោះទាំងនេះ ប្រសិនបើចាំបាច់ ឬក៏ចេញដីកាបន្ថែម មុនពេលបញ្ចប់កិច្ចស៊ើបសួរ។

១៣. ទាក់ទិននឹងសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ចាត់តាំងឱ្យបានត្រឹមត្រូវនូវអ្នកជំនាញដែលមានសមត្ថភាព ស្របតាមវិធាន ៣១(១)ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះ សហចៅក្រមស៊ើបអង្កេត មិនមើលឃើញថា ចាំបាច់សម្រាប់កិច្ចស៊ើបសួររបស់ខ្លួនទេ នៅដំណាក់កាលនេះ។

១៤. ទោះជាដូច្នេះក្ដី សហចៅក្រមស៊ើបអង្កេត មិនមានការជំទាស់ក្នុងការទទួលសារណារបស់អ្នកដែលមិនមែនជាភាគី ដូចមានចែងនៅក្នុងវិធាន ៣៣ នៃវិធានផ្ទៃក្នុងទេ។ ប្រសិនបើមានសារណាទាំងនេះ ត្រូវយោងទៅលើប្រភពដើមនៃការស្រាវជ្រាវរបស់ខ្លួន រួមមានឈ្មោះ ទីកន្លែងរបស់សាក្សីដែលបានសម្ភាសន៍ ព្រមទាំងផ្ដល់នូវការកត់ត្រានានាដែលបានធ្វើនាពេលនោះផងដែរ។ ដោយគិតពីកាលបរិច្ឆេទនៃការដាក់សំណើសុំបន្ថែម និងយោងតាមការប្រកាសជាសាធារណៈអំពីគោលបំណងបិទកិច្ចស៊ើបសួរនោះ សារណាទាំងនេះ គួរត្រូវដាក់ឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៩។

១៥. ទាក់ទិននឹងសំណើសុំចាត់តាំងអ្នកស៊ើបអង្កេតជាស្ត្រី និងអ្នកបកប្រែ ដែលទទួលបានការបណ្ដុះបណ្ដាលពីបញ្ហាយ៉េនឌ័រ ឱ្យធ្វើការស្ដាប់ចម្លើយពាក់ព័ន្ធនឹងការចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ពីភាពចាំបាច់នៃយល់ដឹងអំពីបញ្ហាយ៉េនឌ័រ នៅក្នុងករណីពាក់ព័ន្ធនឹងការផ្ដល់សក្ខីកម្មដែលមានទំនាក់ទំនងនឹងអំពើហិង្សាផ្លូវភេទ និងយ៉េនឌ័រ។ ទោះបីជា នាពេលបច្ចុប្បន្នបុគ្គលិករបស់ ក.ស.ច.ស មិនមានអ្នកស៊ើបអង្កេតជាស្ត្រីក៏ដោយ ក៏ ក.ស.ច.ស នឹងខិតខំបំពេញការងារនេះឱ្យបានប្រសើរបំផុត។

---

25 D188 កថា. ៣០-៣១។

26 D268 កថា.៨(ក)-(ខ)។

១៦. ទាក់ទិននឹងសំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំឱ្យមានការបញ្ជាក់ថា ខ្លួនអាចលើកបញ្ហានេះនៅពេលសវនាការបឋមនោះ សហចៅក្រមស៊ើបអង្កេត សូមបញ្ជាក់ថា វិធានផ្ទៃក្នុង មិនអនុញ្ញាតឱ្យភាគីនានា ធ្វើការប្រកាសអំពីនីតិវិធីដែលត្រូវអនុវត្តនៅដំណាក់កាលជំនុំជម្រះទេ។

## អាស្រ័យហេតុនេះ

១៧. **សម្រេចថា** សំណើសុំដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៩ អាចទទួលយកបាន។

១៨. **សម្រេចទទួលយក** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំ នៅទូទាំងប្រទេសកម្ពុជា។

១៩. **សម្រេចថា** ការកំណត់បទល្មើស នឹងត្រូវធ្វើឡើងនៅពេលចេញដីកាដំណោះស្រាយ បន្ទាប់ពីបានវាយតំលៃលើភស្តុតាងរួចហើយ។

២០. **បញ្ជាក់ថា** ការវាយតំលៃលើបញ្ជីឈ្មោះមនុស្សសម្រាប់ធ្វើការស្តាប់ចម្លើយ គឺកំពុងតែបន្តធ្វើ និងក្នុងករណីចាំបាច់ ដីកានឹងអាចចេញបន្ថែមនៅពេលបិទកិច្ចស៊ើបសួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

Marcel LEMONDE

យូ ប៊ុនឡេង